LAWYERS' COMMITTEE FOR CIVIL RIGHTS AND ECONOMIC JUSTICE
*Serving Greater Boston Since 1968*

# ពាក្យបណ្តឹង អំពីសិទ្ធិបោះឆ្នោត នៅក្រុងឡូវែល

## *(ហួត និង អ្នកផ្សេងទៀត ទល់នឹង សាលាក្រុងឡូវែល និង អ្នកផ្សេងទៀត)*

## សំណួរទូទៅ

**តើពាក្យបណ្តឹងនេះ ស្តីអំពីអ្វី?**

បណ្តឹងនេះ ស្តីអំពីសិទ្ធិចូលរួមឲ្យស្មើភាពគ្នា និង ឲ្យមានភាពយុត្តិធម៌។ ច្បាប់ជាតិចែងថា មនុស្សគ្រប់រូប ត្រូវមានឱកាសស្មើគ្នា ក្នុងការបោះឆ្នោតជ្រើសរើសបេក្ខជន ដែលខ្លួនពេញចិត្ត។ ប៉ុន្តែ ប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រនៅទីក្រុងឡូវែលបច្ចុប្បន្ន មិនបានអនុញ្ញាតឲ្យពលរដ្ឋ មានឱកាសបែបនេះទេ។ ពាក្យបណ្តឹងនេះ ធ្វើឡើងដើម្បីទាមទារ ឲ្យមានការផ្លាស់ប្តូរ របៀបបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង និង សមាជិកគណៈកម្មាធិការសាលារៀន ដើម្បីកែប្រែដំណើរការបោះឆ្នោត ឲ្យមានភាពយុត្តិធម៌ និង ឲ្យមានភាពតំណាងឲ្យពលរដ្ឋទូទៅ ឲ្យបានប្រសើរជាងនេះ។

ទីក្រុងឡូវែល រឹងមាំដោយសារតែភាពចម្រុះជាតិសាសន៍។ ដូច្នេះ មន្ត្រីជាប់ឆ្នោត ត្រូវតែជាអ្នកតំណាងឲ្យភាពចម្រុះជាតិសាសន៍នេះ។ ការផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោតនេះ នឹងនាំមកនូវភាពកាន់តែរឹងមាំ និង ពង្រឹងសិទ្ធិចូលរួមឲ្យស្មើភាពគ្នា និង បង្កើតរដ្ឋាភិបាលមួយ ដែលអាចតំណាងឲ្យផលប្រយោជន៍យើងគ្រប់គ្នា ឲ្យបានប្រសើរជាងនេះ។

**តើមន្ត្រីជាប់ឆ្នោតនៅទីក្រុងឡូវែល ស៊ីគ្នាទៅនឹងភាពចម្រុះជាតិសាសន៍ របស់ក្រុងឡូវែល ដែរឬទេ?**

អត់ទេ! ពលរដ្ឋ ៤៩% ដែលរស់នៅទីក្រុងឡូវែល មានជាតិសាសន៍ខុសៗគ្នា។ សព្វថ្ងៃនេះ ជនជាតិអាមេរិកាំងដើមកំណើតអាស៊ីនៅទីក្រុងឡូវែល មានចំនួនប្រហែល ២២%។ ជនជាតិអាមេរិកាំដើមកំណើតអេស្បាញ/អាហ្វ្រិកឡាទីន មាន ១៨%។ ជនជាតិអាមេរិកាំងដើមកំណើតជនជាតិស្បែកខ្មៅ/អាមេរិកាំងដើមកំណើត

អាហ្វ្រិក មាន ៧%។ ប៉ុន្តែ ទីក្រុងឡូវែល បែរជាមានតែសមាជិកក្រុមប្រឹក្សាក្រុង និង សមាជិកគណៈកម្មាធិការសាលារៀន ជាជនជាតិស្បែកសទាំងអស់គ្រប់គ្រងទៅវិញ។ បេក្ខជនដែលមានជាតិសាសន៍ដទៃចូលរួមឈរឈ្មោះឱ្យគេបោះឆ្នោតច្រើនឆ្នាំមកហើយ ប៉ុន្តែ មានបេក្ខជនជាតិសាសន៍ដទៃ ជាប់ឆ្នោតតិចតួចណាស់។ ជាច្រើនអាណត្តិកន្លងមកនេះ មានតែបេក្ខជនតំណាងមតិភាគតិច តែបួនរូបប៉ុណ្ណោះ ដែលធ្លាប់ជាប់ឆ្នោត ជាសមាជិកក្រុមប្រឹក្សាក្រុង។ បើតាមដឹង មិនដែលមានជនជាតិអាមេរិកាំងដើមកំណើតជាតិសាសន៍ដទៃណាម្នាក់ ធ្លាប់បានជាប់ឆ្នោតជាសមាជិកគណៈកម្មាធិការសាលារៀន ម្តងណានោះទេ សូម្បីតែពីរភាគបី នៃចំនួនសិស្សនៅតាមសាលារដ្ឋនៅទីក្រុងឡូវែល សុទ្ធតែជាកូនចៅរបស់ពលរដ្ឋអាមេរិកាំងដើមកំណើតជាតិសាសន៍ដទៃក៏ដោយ។

ក្នុងសមាជិកក្រុមប្រឹក្សាក្រុងឡូវែល និង គណៈកម្មាធិការសាលារៀន ក៏ខ្វះភាពជាតំណាងឱ្យស្មើភាពគ្នាសម្រាប់តំបន់នៅជុំវិញទីក្រុងនេះដែរ។ ជាប្រពៃណីទៅហើយ ដែលមន្ត្រីជាប់ឆ្នោត ច្រើនតែមកពីតំបន់ ប៊ែលវីឌា (**Belvidere**)។ តំណាងពីតំបន់ផ្សេងទៀត ដូចជាតំបន់ អេឃ័រ (**Acre**) មានតំណាងតិចតួច ឬ ស្ទើរតែគ្មានតំណាងទាល់សោះ ក្នុងសមាជិកក្រុមប្រឹក្សាក្រុង និង គណៈកម្មាធិការសាលារៀន។

***<u>តើប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រនៅទីក្រុងឡូវែល គឺជាអ្វី?</u>***

នៅការិយាល័យបោះឆ្នោត អ្នកបោះឆ្នោត នឹងទទួលបានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត សម្រាប់សមាជិកក្រុមប្រឹក្សាក្រុងឡូវែល និង សមាជិកគណៈកម្មាធិការសាលារៀន។ អ្នកបោះឆ្នោតមានសិទ្ធិគូស ដើម្បីបោះឆ្នោតជ្រើសយក បេក្ខជនឈរឈ្មោះរហូតដល់ ០៩ នាក់ សម្រាប់ក្រុមប្រឹក្សាក្រុង និង ០៦ នាក់សម្រាប់គណៈកម្មាធិការសាលារៀន។ បេក្ខជនម្នាក់ៗ ឈរឈ្មោះតំណាងឱ្យពលរដ្ឋទូទៅ នៅក្រុងឡូវែលទាំងមូល។ បេក្ខជន ០៩ នាក់ដំបូងគេ ដែលឈរឈ្មោះសម្រាប់ក្រុមប្រឹក្សាក្រុង និង បេក្ខជនដំបូងគេ ០៦ នាក់ដែលឈរឈ្មោះសម្រាប់គណៈកម្មាធិការសាលារៀន ដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេ ជាអ្នកជាប់ឆ្នោត។ ដើម្បីជាប់ឆ្នោត បេក្ខជនមិនចាំបាច់ទាល់តែទទួលបានសម្លេងគាំទ្រភាគច្រើន ពីចំណោមអ្នកបោះឆ្នោតសរុបទាំងអស់នោះទេ។

ប៉ុន្តែ ការបោះឆ្នោត“ខណ្ឌ” មានលក្ខណៈខុសគ្នាពីនេះ ដោយសារបើបោះឆ្នោតខណ្ឌ គេបែងចែកទីក្រុងទៅជាខណ្ឌដាច់ពីគ្នា ទៅតាមល្បាយប្រជាពលរដ្ឋ។ អ្នកដែលរស់ក្នុងខណ្ឌណា មានសិទ្ធិបោះឆ្នោតរើសតំណាងខ្លួនសម្រាប់ខណ្ឌនោះ។

**<u>តើហេតុអ្វី បានជាប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រ មិនយុត្តិធម៌?</u>**

តុលាការបានសម្រេចសេចក្តីថា ប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រ មិនយុត្តិធម៌ និង មិនស្របច្បាប់ ប្រសិនបើការបោះឆ្នោតតាមប្រព័ន្ធបែបនេះ នាំឲ្យបាត់សំឡេងពលរដ្ឋសហគមន៍ ដែលជាជនជាតិអាមេរិកាំងដើមកំណើតជាតិសាសន៍ដទៃ។ ប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រ អនុញ្ញាតឲ្យសំឡេងគាំទ្រភាគច្រើន ៥១% ដែលមានអំណាចរាំងខ្ទប់សំឡេងជនជាតិភាគតិច ប្រមូលយកអាសនៈទាំងអស់។ ជាលទ្ធផលពួកគេ បន្តឈ្នះឆ្នោត ប្រមូលយកទាំងអស់បែបនេះ ជារៀងរហូត។ ទីក្រុងធំៗ និង ទីប្រជុំជនភាគច្រើន នៅរដ្ឋម៉ាសាឈូសេតលែងប្រើប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រនេះអស់ហើយ ដោយសារពួកគេទទួលស្គាល់ អំពីភាពអយុត្តិធម៌បែបនេះ។

**<u>ខ្ញុំនៅតែមិនទាន់យល់។ បើគេឈ្នះសំឡេងភាគច្រើន បានន័យថាយុត្តិធម៌ ហេតុអ្វីថាមិនយុត្តិធម៌?</u>**

ជាការយុត្តិធម៌ បើការបោះឆ្នោតមួយ មានអាសនៈតែមួយ (ឧទាហរណ៍ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា) ហើយអ្នកដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេ ជាអ្នកជាប់ឆ្នោត។ ប៉ុន្តែ បញ្ហានឹងកើតមាន បើការបោះឆ្នោត ប្រកួតដណ្តើមអាសនៈច្រើន។ បើ<u>អាសនៈទាំងអស់</u> ត្រូវតែប្រគល់ទៅឲ្យក្រុមបេក្ខជន ដែលមានសំឡេងគាំទ្រភាគច្រើន ៥១% ដែលមានអំណាចរាំងខ្ទប់សំឡេងជនជាតិភាគតិច <u>គ្រប់ការបោះឆ្នោត</u>បែបនេះមតិភាគតិច ច្បាស់ជាគ្មានសំឡេងទាល់តែសោះ។ ការបោះឆ្នោតបែបនេះ ធ្វើឲ្យបាត់សំឡេងរបស់មតិភាគតិចជារៀងរហូត។

**<u>ខ្ញុំយល់ហើយ។ ប៉ុន្តែ បើមិនយុត្តិធម៌ដូច្នេះ តើប្រព័ន្ធបែបនេះ ខុសច្បាប់ឬទេ?</u>**

ច្បាប់ស្តីពីការបោះឆ្នោតជាតិឆ្នាំ ១៩៦៥ ហាមឃាត់“បទដ្ឋាន ការអនុវត្ត ឬ នីតិវិធី”ណាមួយដែល“នាំឲ្យបដិសេធសិទ្ធិ ឬ ធ្វើឲ្យបាត់បង់សិទ្ធិបោះឆ្នោតរបស់ពលរដ្ឋសហរដ្ឋអាមេរិក ដោយសារតែមូលហេតុជាតិសាសន៍ ឬ ព័ណ៌សម្បុរ”។ ប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រ ដូចកំពុងអនុវត្តនៅទីក្រុងឡូវែល ត្រូវបានចាត់

ទុកថាមិនស្របច្បាប់ បើតាមច្បាប់ស្តីពីសិទ្ធិបោះឆ្នោត ដោយសារប្រព័ន្ធបែបនេះ ធ្វើឲ្យបាត់បង់សំឡេងឆ្នោតរបស់សហគមន៍ ដែលមានដើមកំណើតពីជាតិសាសន៍ដទៃ។ កន្លងមក ការតវ៉ាឲ្យផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រនេះ ទទួលបានជោគជ័យ នៅទូទាំងប្រទេស។

**<u>តើទីក្រុងដទៃទៀត នៅរដ្ឋម៉ាសាឈូសេត ប្រើប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រនេះដែរឬទេ?</u>**

មានមិនច្រើនទេ។ ទីក្រុងឡូវែល ជាទីក្រុងចុងក្រោយគេបង្អស់ នៅរដ្ឋម៉ាសាឈូសេត ដែលមានប្រជាជនលើសពីមួយសែននាក់ ប៉ុន្តែ នៅប្រើប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រដូច្នេះ។ ទីក្រុងជាច្រើននៅរដ្ឋម៉ាសាឈូសេតបានផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោតបែបនេះអស់ហើយ ទាំងផ្លាស់ប្តូរដោយសារការប្តឹងឲ្យផ្លាស់ប្តូរតាមផ្លូវតុលាការ ឬគេប្តូរទៅជាការបោះឆ្នោត ជ្រើសរើសអាសនៈតាមខណ្ឌនីមួយៗវិញ ឬ ក្រុងខ្លះគេប្រើប្រព័ន្ធចម្រុះទាំងប្រព័ន្ធមិនសមាមាត្រ និង ប្រព័ន្ធបោះឆ្នោតតាមខណ្ឌមួយៗនេះ។ ទីក្រុង បូស្តុន, ស្ព្រីងហ្វៀល, វ័រស្ទើរ និង ក្រុងផ្សេងទៀតបានផ្លាស់ប្តូរប្រព័ន្ធនេះ រួចហើយ។

**<u>តើហេតុអ្វី បានជាប្រព័ន្ធបោះឆ្នោត ឲ្យមានតំណាងស្មើគ្នា មានសារសំខាន់?</u>**

បើគ្មានតំណាងគ្រប់គ្រាន់ នៅក្នុងជួររដ្ឋាភិបាលក្រុង សេចក្តីត្រូវការជាក់ស្តែងរបស់ពលរដ្ឋក្នុងសហគមន៍ ដែលមានព័ណ៌សម្បុរផ្សេង ច្បាស់ជាគ្មាន គេយកចិត្តទុកដាក់នោះទេ។

ឧទាហរណ៍ ទីក្រុងឡូវែលសព្វថ្ងៃ កំពុងស្ថិតក្នុងដំណាក់កាលផ្លាស់ទីតាំងសាលាវិទ្យាល័យរដ្ឋរបស់ឡូវែល។ នេះជាបញ្ហាសំខាន់មួយ សម្រាប់ពលរដ្ឋទាំងអស់ ដែលរស់នៅទីក្រុងឡូវែល រួមមានសហគមន៍ដែលមានព័ណ៌សម្បុរផ្សេងផង (ដោយសារតែពីរភាគបី នៃសិស្សនៅសាលារដ្ឋក្នុងទីក្រុងឡូវែល ជាកូនចៅពលរដ្ឋដែលមានព័ណ៌សម្បុរផ្សេង)។ ប៉ុន្តែ ទាល់តែជិតចប់ដំណើរការទៅហើយ ទើបមានការផ្សព្វផ្សាយ ឬ ជូនដំណឹងដល់ពលរដ្ឋសហគមន៍ជនជាតិភាគតិច ឲ្យបានជ្រាបអំពីបញ្ហានេះ។ ម្យ៉ាងទៀត ការប្រឹងប្រែងចង់ឲ្យសហគមន៍ជនជាតិភាគតិច បានចូលរួមគិត និង ពិភាក្សារឿងធំបែបនេះ មានតិចតួចណាស់។

ដូចគ្នានេះដែរ ពលរដ្ឋម្នាក់បានដាក់ញត្តិ ទៅក្រុមប្រឹក្សាក្រុង សុំឲ្យជួយកាត់បន្ថយកិច្ចសហប្រតិបត្តិការរបស់មន្ត្រីពង្រឹងការអនុវត្តច្បាប់របស់មូលដ្ឋាន ជាមួយនឹងអាជ្ញាធរអន្តោប្រវេសន៍ជាតិ។ ក្រុមប្រឹក្សាក្រុងបាន

បដិសេធ មិនធ្វើគោលនយោបាយណាមួយ ដើម្បីឆ្លើយតបទៅនឹងសំណើនេះទេ។ម្យ៉ាងទៀតក្រុមប្រឹក្សាក្រុង មានការទទួលស្គាល់តិចតួចណាស់ អំពីកង្វល់ជាច្រើនរបស់ពលរដ្ឋដែលជាជនអន្តោប្រវេសន៍ ជុំវិញបញ្ហានេះ។

ការខ្វះភាពជាអ្នកតំណាងរបស់សហគមន៍បែបនេះ ក៏បណ្តាលឲ្យការផ្តល់សេវាជាមូលដ្ឋានទូទៅ មិនស្មើភាពគ្នា ដល់ពលរដ្ឋសហគមន៍ទាំងអស់។ ឧទាហរណ៍ គ្រាន់តែភ្លើងបំភ្លឺសួនប៉ៃលិន (**Clemente Park**) ត្រូវការពេលរាប់ឆ្នាំ ទម្រាំដោះស្រាយបាន។ សួននេះ ជាទីដែលសមាជិកជាច្រើននៃសហគមន៍ជនជាតិភាគតិចនៅទីក្រុងឡូវែល នាំគ្នាប្រើជាញឹកញាប់។ បើនិយាយពីសេវាបកប្រែភាសាវិញ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាក្រុងឡូវែល និង គណៈកម្មាធិការសាលារៀន ស្ទើរតែគ្មានទាល់តែម្តង។ អ្នកមិនចេះនិយាយភាសាអង់គ្លេស មិនដឹងគេប្រជុំអំពីអ្វី និង មិនអាចចូលរួមក្នុងការសម្រេចធំៗបាននោះទេ។

## <u>តើដើមបណ្តឹងជានរណា?</u>

ដើមបណ្តឹងជាបណ្តុំនៃពលរដ្ឋដែលរស់នៅទីក្រុងឡូវែល ដែលចង់ធ្វើឲ្យទីក្រុងរបស់ពួកគាត់ មានភាពរឹងមាំជាងនេះ ដោយការផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោតដែលគ្មានយុត្តិធម៌ និង បើកផ្លូវផ្តល់ឱកាសស្មើគ្នា ឲ្យពលរដ្ឋនៅទីក្រុងឡូវែលទាំងអស់គ្នា អាចបោះឆ្នោតជ្រើសរើសតំណាង ទៅតាមការប្រាថ្នាចង់បានរបស់ខ្លួន។ ដើមបណ្តឹងជាបណ្តុំពលរដ្ឋជាច្រើនក្រុម មានជនជាតិអាមេរិកាំងដើមកំណើតអាស៊ី មានជនជាតិអាមេរិកាំងដើមកំណើតអេស្ប៉ាញ/អាហ្វ្រិកឡាទីន មានទាំងចាស់ មានទាំងក្មេង និង ដើមបណ្តឹងជាច្រើនជាពលរដ្ឋដែលរស់នៅទីក្រុងឡូវែលយូរឆ្នាំមកហើយ។ ដើមបណ្តឹងសុទ្ធតែមានបំណង ចង់ធ្វើឲ្យទីក្រុងរបស់ខ្លួន កាន់តែរឹងមាំ ដោយធ្វើឲ្យប្រព័ន្ធបោះឆ្នោតមួយ មានលក្ខណៈប្រសើរ ឆ្លើយតបទៅតាមភាពចម្រុះជាតិសាសន៍នៃទីក្រុងឡូវែល។

## <u>តើនរណាជាចុងបណ្តឹង?</u>

ចុងបណ្តឹង គឺសាលាក្រុងឡូវែល អ្នកគ្រប់គ្រងសាលាក្រុង ក្រុមប្រឹក្សាក្រុង គណៈកម្មាធិការសាលារៀន និង គណៈកម្មាធិការរៀបចំការបោះឆ្នោត និង ជំរឿន។

**តើពាក្យបណ្ដឹងនេះ ទាមទារឲ្យពង្រឹងការអនុវត្តច្បាប់អ្វី?**

បន្ថែមលើច្បាប់ជាតិស្ដីពីការបោះឆ្នោត ពាក្យបណ្ដឹងនេះចោទប្រកាន់ អំពីការរំលោភបំពានច្បាប់វិសោធនកម្ម លើកទី ១៤ និង ១៥ នៃរដ្ឋធម្មនុញ្ញនៃសហរដ្ឋអាមេរិក។

**តើតុលាការមួយណា នឹងធ្វើសវនាការ ក្នុងរឿងនេះ?**

សំណុំរឿងនេះ កំពុងស្ថិតក្នុងដៃតុលាការជាតិ ប្រចាំរដ្ឋម៉ាសាឈូសេត។ ចៅក្រមដែលកាន់សំណុំរឿងនេះ ឈ្មោះ វីល្លៀម ជី យ៉ាំង (**Honorable William G. Young**)។

**តើក្របខណ្ឌផែនការ E គឺជាអ្វី? តើពាក្យបណ្ដឹងនេះ មានន័យថាទីក្រុងឡូវែល មិនអាចក្លាយជាទីក្រុង ក្នុងក្របខណ្ឌផែនការ E បានទេឬ?**

ក្នុងក្របខណ្ឌផែនការ **E** ពលរដ្ឋនៃទីក្រុងឡូវែល បោះឆ្នោតជ្រើសរើសសមាជិក ០៩ រូបសម្រាប់ក្រុមប្រឹក្សាក្រុង សម្រាប់អាណត្តិ ០២ ឆ្នាំ។ បន្ទាប់មក ក្រុមប្រឹក្សាក្រុងបោះឆ្នោតជ្រើសសមាជិកម្នាក់ក្នុងចំណោម ០៩ នាក់នេះ ដើម្បីធ្វើជាអភិបាលក្រុង ដែលមានងារជាប្រមុខដឹកនាំទីក្រុង ដោយត្រូវធ្វើជាអធិបតីក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង និង គណៈកម្មាធិការសាលារៀន។ អ្នកគ្រប់គ្រងក្រុងម្នាក់ នឹងត្រូវតែងតាំង ដើម្បីចាត់ចែងក្រុង។

ពាក្យបណ្ដឹងនេះ មិនរាំងរាំងក្រុងឡូវែល មិនឲ្យអនុវត្តក្របខណ្ឌផែនការ **E** ដើម្បីបង្កើតរដ្ឋាភិបាលនោះទេ។ ទីក្រុងឡូវែល នៅតែជាទីក្រុងដែលអនុវត្តតាមក្របខណ្ឌផែនការ **E** ដដែល ប៉ុន្តែឈប់ប្រើប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រនេះ។ ឧទាហរណ៍ ដូចជានៅទីក្រុង វ័រស្ទើរ និង ខែមប្រ៊ិច ប្រើប្រាស់ទម្រង់ក្របខណ្ឌផែនការ **E** នៃការបង្កើតរដ្ឋាភិបាល ដោយមានតំណែងអ្នកគ្រង់គ្រងក្រុងម្នាក់។ ទីក្រុង វ័រស្ទើរ មានសមាជិក ១១ នាក់ នៅក្នុងក្រុមប្រឹក្សាក្រុង ដែលជាប់ឆ្នោតតាមរយៈការបោះឆ្នោតចម្រុះតាមខណ្ឌ និង ប្រព័ន្ធមិនសមាមាត្រ។ ទីក្រុងខែមប្រ៊ិច មានសមាជិកក្រុមប្រឹក្សាក្រុង ០៩ រូប និង ប្រើប្រាស់ប្រព័ន្ធបោះឆ្នោត តាមទម្រង់“សមាមាត្រ”។

## **តើលោកអ្នក ចង់បានប្រព័ន្ធបោះឆ្នោតបែបណា?**

យើងយល់ថា ប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រក្នុងពេលបច្ចុប្បន្ននេះ មិនស្របច្បាប់ និងត្រូវតែផ្លាស់ប្តូរ។ ពាក្យបណ្តឹងនេះ ទាមទារឲ្យផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាក្រុងឡូវែល និង គណៈកម្មាធិការសាលារៀន ដើម្បីឲ្យមានប្រព័ន្ធមួយប្រសើរ មានយុត្តិធម៌ ដូចប្រព័ន្ធបោះឆ្នោតតាមខណ្ឌដែរ។ ទីក្រុងជាច្រើននៅរដ្ឋម៉ាសាឈូសេត ប្រើប្រាស់ប្រព័ន្ធបោះឆ្នោតចម្រុះ ទាំងប្រព័ន្ធបែបមិនសមាមាត្រ និង ប្រព័ន្ធបោះឆ្នោតតាមខណ្ឌ។ ប្រព័ន្ធចម្រុះបែបនេះ អាចជាដំណោះស្រាយមួយសមស្រប។

## **ហេតុអ្វីចាំបាច់ ដាក់ពាក្យបណ្តឹងបែបនេះ?**

ការដាក់ពាក្យបណ្តឹងនេះ គឺដោយសារការស្វះស្វែងតាមមធ្យោបាយផ្សេង ដើម្បីឲ្យផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោតនេះ មិនទទួលបានជោគជ័យ។ សាលាក្រុងមានឱកាសផ្លាស់ប្តូរប្រព័ន្ធនេះ ច្រើនលើកច្រើនគ្រាមកហើយ ប៉ុន្តែ បដិសេធមិនដោះស្រាយ៖

- ឧទាហរណ៍ ក្នុងឆ្នាំ ២០០៩ មានសំណើមួយស្នើឡើងនៅលើសន្លឹកឆ្នោត ដើម្បីសុំឲ្យសាលាក្រុងផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោតនេះ។ ពលរដ្ឋអាមេរិកាំងដើមកំណើតអេស្ប៉ាញ/អាហ្វ្រិកឡាទីន និង ពលរដ្ឋអាមេរិកាំងដើមកំណើតអាស៊ី ដ៏ច្រើនលើសលុប នាំគ្នាបោះឆ្នោតគាំទ្រការធ្វើប្រជាមតិនេះ។ ប៉ុន្តែ ដោយសារតែប្រព័ន្ធសំឡេងភាគច្រើន ដែលមានសិទ្ធិរាំងខ្ទប់សំឡេងមតិភាគតិចនេះ ពោលគឺ ២ ទល់នឹង ១ ទើបធ្វើសំណើនោះត្រូវបរាជ័យ។
- នៅឆ្នាំ ២០១០ និង ២០១១ មានសំណើមួយទៀត ស្នើឲ្យក្រុមប្រឹក្សាក្រុង ពិចារណាផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោតនេះ។ ក្រុមប្រឹក្សាក្រុងយល់ព្រមពិភាក្សាសំណើនេះ។ ប៉ុន្តែ គ្មានបានលទ្ធផលអ្វីទាំងអស់។
- នៅឆ្នាំ ២០១៦ សមាជិកក្រុមប្រឹក្សាក្រុងមួយរូប បានស្នើជាថ្មីម្តងទៀត សុំឲ្យក្រុមប្រឹក្សាក្រុងពិភាក្សាផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោតបច្ចុប្បន្ន។ គ្មានសមាជិកក្រុមប្រឹក្សាក្រុងណាម្នាក់ផ្សេង គាំទ្រសំណើនេះទេ។ បញ្ហានេះបានរសាត់បាត់ទៅ ដោយគ្មានការពិភាក្សាអ្វីទាំងអស់។

## **តើក្រុមមេធាវីណាខ្លះ ដែលតំណាងឲ្យដើមបណ្តឹង?**

គណៈកម្មាធិការមេធាវី ដើម្បីសិទ្ធិពលរដ្ឋ និង យុត្តិធម៌ផ្នែកសេដ្ឋកិច្ច (**LCCR**) និង ក្រុមហ៊ុនមេធាវី **Ropes & Gray** ជាក្រុមមេធាវីតំណាងឲ្យដើមបណ្តឹង។ គណៈកម្មាធិការមេធាវី **LCCR** ជាអង្គការផ្នែក

ច្បាប់មិនរកប្រាក់កម្រៃ ដែលប្តូរផ្តាច់ការពារសិទ្ធិពលរដ្ឋ និង យុត្តិធម៌សម្រាប់ពូជសាសន៍។ ក្រុមហ៊ុនមេធាវី **Ropes & Gray** ជាក្រុមហ៊ុនឯកជន ដែលផ្តល់សេវាផ្នែកច្បាប់ *ដោយស្ម័គ្រចិត្ត* ឥតយកប្រាក់កម្រៃ។

## តើមជ្ឈដ្ឋានណាខ្លះ និយាយអំពីពាក្យបណ្តឹងនេះ?

ការដាក់ពាក្យបណ្តឹងនេះ ទទួលបានការចាប់អារម្មណ៍ យ៉ាងច្រើនពីប្រព័ន្ធផ្សព្វផ្សាយ មានដូចជា៖ សារព័ត៌មានឡូវែលសាន់ (**Lowell Sun**) បូស្តុនហ្គ្លោប (**Boston Globe**) ទីភ្នាក់ងារព័ត៌មាន **Associated Press** ប៉ុស្តិ៍វិទ្យុ **WGBH** (ចុចនៅទីនេះ នៅទីនេះ និង នៅទីនេះ) ទស្សនាវដ្តីរបស់រដ្ឋ **Commonwealth Magazine**, ទូរទស្សន៍ **Fox 25**, ទូរទស្សន៍ **LTC News**, **Telemundo,** និងសារព័ត៌មានសហគមន៍អាមេរិកាំងដើមកំណើតអាហ្វ្រិកឈ្មោះ **the Bay State Banner**។

កាសែត បូស្តុនហ្គ្លោប (**Boston Globe**) បានចុះផ្សាយបទវិចារណកថាមួយ ក្រោមចំណោមជើងថា៖ "ទីក្រុងឡូវែល គួររំលាយប្រព័ន្ធបោះឆ្នោតបែបមិនសមាមាត្រ" ដោយអំពាវនាវឲ្យ "ក្រុងឡូវែល ដែលជាក្រុងសម្បូរទៅដោយជនអន្តោប្រវេសន៍ ដោះស្រាយពាក្យបណ្តឹង និង បង្កើតរដ្ឋាភិបាលមួយ ដែលមានលក្ខណៈជាតំណាងឲ្យម្ចាស់ឆ្នោត ល្អប្រសើរជាងនេះ"។

## តើធ្វើយ៉ាងដូចម្តេច ទើបខ្ញុំអាចទទួលបានព័ត៌មានជាប្រចាំ អំពីរឿងក្តីនេះ?

គណៈកម្មាធិការមេធាវី ដើម្បីសិទ្ធិពលរដ្ឋ និង យុត្តិធម៌ផ្នែកសេដ្ឋកិច្ច (**LCCR**) មានព័ត៌មានអំពីពាក្យបណ្តឹងនេះ នៅលើគេហទំព័ររបស់ខ្លួន (**www.lawyerscom.org**) និង បន្តផ្សាយព័ត៌មានបច្ចុប្បន្នភាពនៅលើគេហទំព័រនេះ។